UNITED NATIONS
CAMBODIA

# ការឆ្លើយតបចំពោះជំងឺកូវីដ-១៩ របស់អង្គការសហប្រជាជាតិនៅកម្ពុជា
# អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសុខភាពផ្លូវភេទ និងបន្តពូជ
# ឯកសារព័ត៌មានទី ៦
# ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០២១

ក្នុងអំឡុងពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងជាពិសេសអំពើហិង្សាក្នុងគ្រួសារ មានការកើនឡើងយ៉ាងគំហុកនៅទូទាំងពិភពលោក។ ខណៈពេលដែលមានការអនុវត្តវិធានការបិទខ្ទប់ ក្នុងប្រទេសជាច្រើន ការទទួលបានសេវា និងយុត្តិធម៌សម្រាប់អ្នកដែលរួចរស់ពីអំពើហិង្សា ក៏ដូចជា កិច្ចខិតខំប្រឹងប្រែងទប់ស្កាត់អំពើហិង្សា មានការថយចុះក្នុងកម្រិតមួយគួរឱ្យបារម្ភ។ ការប៉ាន់ស្មាន ដែលធ្វើឡើងកាលពីពេលថ្មីៗនេះ នៅក្នុងសកលលោកទាំងមូល បង្ហាញថា សម្រាប់រៀងរាល់រយៈពេល ៣ ខែ នៃការបិទខ្ទប់ទីក្រុង មានស្ត្រីចំនួន ១៥ លាននាក់បន្ថែមទៀត ទទួលរងផលប៉ះពាល់ដោយសារអំពើហិង្សា។[1] នៅក្នុងខែ មេសា ឆ្នាំ ២០២០ អគ្គលេខាធិការអង្គការសហប្រជាជាតិ បានជំរុញឱ្យរដ្ឋាភិបាលទាំងអស់ចាត់ទុកការទប់ស្កាត់ និងការឆ្លើយតបចំពោះករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ថាជាផ្នែកមួយដ៏សំខាន់នៃផែនការឆ្លើយតប ចំពោះជំងឺកូវីដ-១៩ នៅក្នុងប្រទេសរបស់ពួកគេ។

អំពើហិង្សាលើស្ត្រី គឺជាការរំលោភបំពានសិទ្ធិមនុស្សមួយ ក្នុងចំណោមករណីរំលោភបំពានសិទ្ធិមនុស្ស ដែលកើតមានទូទៅជាងគេនៅក្នុងសកលលោក ហើយបានបង្កផលប៉ះពាល់យ៉ាងធំធេងមកលើសុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់ស្ត្រី។ នៅកម្ពុជា ក្នុងចំណោមស្ត្រី ៥នាក់ មានប្រហែលជា ១នាក់ ដែលរាយការណ៍ថាបានទទួលរងអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទ ពីដៃគូស្និទ្ធស្នាល នៅក្នុងជីវិតរបស់ពួកគេ។[2] ក្នុងចំណោមកុមារ ២នាក់ មាន ១នាក់ ដែលទទួលរងការវាយដំធ្ងន់ធ្ងរ។ ក្នុងចំណោមកុមារ ៤នាក់ មាន ១នាក់ ដែលទទួលរងការរំលោភបំពានផ្លូវចិត្ត ហើយក្នុងចំណោមកុមារី និងកុមារា ២០នាក់ មាន ១នាក់ ដែលធ្លាប់ទទួលរងការឈ្លានពានផ្លូវភេទមកលើពួកគេ។[3]

អំពើហិង្សាលើស្ត្រី និងក្មេងស្រី ធ្វើឱ្យសង្គមត្រូវខាតបង់ផ្នែកសេដ្ឋកិច្ចដ៏ច្រើន។ អំពើហិង្សាប្រភេទនេះ បង្កផលប៉ះពាល់អវិជ្ជមានដល់ការចូលរួមរបស់ស្ត្រីនៅក្នុងការអប់រំ ការងារ និងជីវិតរបស់ពួកគេក្នុងនាមជាពលរដ្ឋ និងធ្វើឱ្យរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ។ អំពើហិង្សាលើស្ត្រី និងក្មេងស្រី នាំឱ្យ

[1] ឯកសារបច្ចេកទេសរបស់ UNFPA "ផលប៉ះពាល់នៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ លើសេវាផែនការគ្រួសារ និងការបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ការកាត់ច្រើបប្រដាប់ភេទរបស់ស្ត្រី និងការរៀបអាពាហ៍ពិពាហ៍របស់កុមារ" ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២០។

[2] ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ ២០១៤។

[3] ការអង្កេតអំពើហិង្សាលើកុមារនៅកម្ពុជា (CVACS) ឆ្នាំ ២០១៣។

មានការបាត់បង់ការងារ និងផលិតភាព និងធ្វើឱ្យប្រព័ន្ធផ្តល់សេវាសង្គម ប្រព័ន្ធយុត្តិធម៌ស្ថា ប័នផ្តល់សេវាថែទាំសុខភាព និងនិយោជក ខាតបង់ធនធានជាច្រើន។ ដូច្នេះ អំពើហិង្សាលើស្ត្រី គឺជាឧបសគ្គដ៏ជាក់ច្បាស់មួយដែលធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់កម្ពុជា។

អង្គការសហប្រជាជាតិ ផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងដល់ការបង្កើនលទ្ធភាពរបស់ស្ត្រី និងក្មេងស្រីនៅកម្ពុជា ក្នុងការទទួលបានសេវាចាំបាច់សំខាន់ៗ។ ក្នុងពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ អង្គការសហប្រជាជាតិ បានការចាត់ទុកការគាំទ្រដល់ក្រសួងកិច្ចការនារី និងអ្នកផ្តល់សេវាជាអង្គការសង្គមស៊ីវិល ថាជាការងារអាទិភាព ដើម្បីធានាថាការផ្តល់សេវាចាំបាច់សំខាន់ៗ ជូនអ្នករួចរស់ពីអំពើហិង្សាលើស្ត្រី/អំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅតែមានការសម្របសម្រួលបានល្អ ដែលធ្វើឲ្យសេវាទាំងនេះងាយស្រួលទទួលបាន និងនៅតែមានដំណើរការ តាមរយៈការប្រើប្រាស់ទម្រង់ផ្តល់សេវាអនឡាញ នៅពេលដែលអាចធ្វើទៅបាន។ លើសពីនេះ ក៏មានការផ្សព្វផ្សាយព័ត៌មានអំពីសេវាដែលមានផងដែរ ជាពិសេសដល់ក្រុមដែលទំនងជាត្រូវបានគេទុកចោល។

ការផ្តល់ជំនួយរបស់អង្គការសហប្រជាជាតិ ក៏រួមមានការគាំទ្រដល់សេវាសុខភាពសុខភាព និងសេវាសង្គមផងដែរ ដើម្បីធានាឱ្យមានការបន្តផ្តល់ការថែទាំដល់អ្នករួចរស់ពីអំពើហិង្សាទាក់ទងយេនឌ័រ ដូចជា (i) ការផ្តល់ការបំពាក់បំប៉នដល់អ្នកផ្តល់សេវានៅក្នុងទីក្រុងភ្នំពេញ និងខេត្តចំនួន ១១ តាមរយៈការផ្តល់ឱ្យពួកគេនូវចំណេះដឹង និងជំនាញអំពីសេវាចាំបាច់សំខាន់ៗ ដែលឆ្លើយតបចំពោះយេនឌ័រ ដូចជា ការគ្រប់គ្រងករណីជំនាញផ្តល់ប្រឹក្សាតាមប្រព័ន្ធអនឡាញ និងជំនាញផ្តល់ប្រឹក្សាកម្រិតមូលដ្ឋានដល់អ្នករួចរស់ពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (ii) ការធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយ កម្រងព័ត៌មានទំនាក់ទំនងរបស់អ្នកផ្តល់សេវា ដល់អ្នកដែលរួចរស់ពីអំពើហិង្សាទាក់ទងយេនឌ័រ (iii) ការអប់រំ ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះករណីអំពើហិង្សាលើស្ត្រី ក្នុងអំឡុងពេលដែលមានការរាតត្បាតជាសកល តាមរយៈបណ្តាញទំនាក់ទំនងសង្គម ដោយបានផ្សព្វផ្សាយដល់មនុស្សចំនួន ៣៦០ ០៥៦ នាក់ និង (iv) ការផ្តល់ជំនួយសម្រាប់ការរៀបចំគោលការណ៍ណែនាំស្តីពីការធានាសុវត្ថិភាពរបស់ស្ត្រី និងកុមារ ដែលកំពុងស្ថិតនៅក្នុងមណ្ឌលចត្តាឡីស័ករបស់រដ្ឋ។

ចាប់តាំងពីពេលដែលការរាតត្បាតជាសកលចាប់ផ្តើមកើតឡើង ចំនួននៃការហៅទូរស័ព្ទទៅកាន់បណ្តាញផ្តល់ជំនួយ និងខ្សែទូរស័ព្ទរាយការណ៍ព័ត៌មានទាន់ហេតុការណ៍នៅកម្ពុជា មានការកើនឡើង[4] ជាពិសេស ការហៅទូរស័ព្ទដើម្បីសុំការគាំទ្រចំពោះការបារម្ភពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ បញ្ហាសុខភាពផ្លូវចិត្ត ការខ្វះស្បៀង និងបញ្ហាសុវត្ថិភាពជាដើម។ អង្គការសហប្រជាជាតិកំពុងផ្តល់ជំនួយផ្ទាល់ដល់បណ្តាញជំនួយកុមារ/ខ្សែទូរស័ព្ទរាយការណ៍ព័ត៌មានទាន់ហេតុការណ៍ទាំងនេះ និងបានគាំទ្រដល់ការរៀបចំសេចក្តីណែនាំស្តីពីការផ្តល់សេវា តាមរយៈខ្សែទូរស័ព្ទបណ្តាញជំនួយផងដែរ។ អង្គការសហប្រជាជាតិក៏កំពុងធ្វើការងារ ដើម្បីពង្រឹង

[4] របាយការណ៍ដែលបានទទួលពីខ្សែទូរស័ព្ទផ្តល់ជំនួយដោយមិនគិតថ្លៃ ដែលគ្រប់គ្រងដោយ បណ្តាញជំនួយកុមារកម្ពុជា (CHC) បង្ហាញថា នៅមុនពេលដែលមានការអនុវត្តវិធានការបិទខ្ទប់ ដោយសារការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ CHC បានទទួលការហៅទូរស័ព្ទចំនួន ២.៦០០ ដង ក្នុងមួយខែ។ ក្នុងអំឡុងពេលដែលមានការអនុវត្តវិធានការបិទខ្ទប់ដោយសារតែជំងឺកូវីដ-១៩ ការហៅទូរស័ព្ទនេះកើនឡើងពី ២.៦០០ ដង ក្នុងមួយខែ ដល់ ៤.១០០ ដងក្នុងមួយខែ។

សមត្ថភាពឆ្លើយតបចំពោះតម្រូវការការពារ និងការសម្របសម្រួលការបញ្ជូនទៅរកសេវាដែលចាំបាច់ផងដែរ។

អង្គការសហប្រជាជាតិបន្តផ្តល់ការគាំទ្រដល់ក្រុមដែលងាយរងគ្រោះជាងគេ តាមរយៈការពង្រឹងបណ្តាញដែលដឹកនាំដោយស្ត្រីនៅតាមសហគមន៍ចំនួន ១៥ ក្នុងការផ្តល់ការគាំទ្រផ្នែកផ្លូវចិត្តសង្គមដល់គ្នាទៅវិញទៅមក ដល់ពលករទេសន្តប្រវេសន៍ជាស្ត្រី ដែលវិលត្រឡប់មកស្រុកកំណើតវិញ ហើយដែលកំពុងស្នាក់នៅក្នុងមណ្ឌលចត្តាឡីស័ក និងដើម្បីជួយឱ្យស្ត្រីទាំងនោះអាចធ្វើសមាហរណកម្មទៅក្នុងសហគមន៍របស់ពួកគេវិញ។ កញ្ចប់សម្ភារប្រើប្រាស់ចាំបាច់ចំនួន ២ ១០០ កញ្ចប់ ត្រូវបានផ្តល់ដល់ពលករទេសន្តប្រវេសន៍ជាស្ត្រីងាយរងគ្រោះ ដែលវិលត្រឡប់មកស្រុកកំណើតវិញ និងដល់ស្ត្រី និងក្មេងស្រី ដែលប្រឈមនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងខេត្តចំនួន ៨។ លើសពីនេះ ក៏មានការអន្តរាគមន៍ផ្តោតលើការការពារកុមារ ដែលជាកូនរបស់ពលករទេសន្តប្រវេសន៍ ដែលត្រូវត្រឡប់មកកម្ពុជា ពីប្រទេសថៃវិញ កាលពីឆ្នាំ ២០២០ ដោយសារការបិទព្រំដែន ផងដែរ។ ជាលទ្ធផលមានកុមារ មាតាបិតា និងអ្នកផ្តល់ការថែទាំជិត ៨០ ០០០នាក់ បានទទួលការយល់ដឹង តាមរយៈសកម្មភាពបង្កើនការយល់ដឹង និងការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត និងចិត្តសង្គម (MHPSS) និងមានអ្នកផ្តល់សេវាចំនួន ៥០០នាក់ បានបង្កើនសមត្ថភាព ផ្តល់ការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត និងចិត្តសង្គម និងការកាត់បន្ថយហានិភ័យនៃអំពើហិង្សាទាក់ទងយេនឌ័រ (GBV)។

ដើម្បីការពារកុមារ មានការអនុម័តដាក់ឲ្យអនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងករណី ក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ ដែលត្រូវបានកែសម្រួលថ្មី និងការណែនាំអំពីការធានាសុវត្ថិភាពកុមារនៅតាមមណ្ឌលថែទាំ និងមានភ្នាក់ងារសង្គមកិច្ចចំនួន ៥៨៣ នាក់ បានទទួលការបណ្តុះបណ្តាលអំពីការអនុវត្តគោលការណ៍ណែនាំនេះ ក្រោមជំនួយពីអង្គការសហប្រជាជាតិ។ ជាលទ្ធផល មានកុមារយ៉ាងហោចណាស់ ១២ ៧៤៣ នាក់ (ស្រី ៥ ៦៣៩នាក់) ដែលបានទទួលរងអំពើហិង្សា បានទទួលសេវាសង្គម សេវាសុខភាព និងសេវាយុត្តិធម៌ ចាប់តាំងពីឆ្នាំ ២០២០ មក។

***<u>សុខភាព និងសេវាផ្លូវភេទ និងបន្តពូជ</u>***

តាមរយៈការសហការយ៉ាងជិតស្និទ្ធ ជាមួយនឹងមជ្ឈមណ្ឌលជាតិសុខភាពមាតានិងកុមារនៃក្រសួងសុខាភិបាល អង្គការសហប្រជាជាតិនៅកម្ពុជាបានផ្តល់ការគាំទ្រដល់ការរៀបចំគោលការណ៍ណែនាំជាតិស្តីពីការធានានិរន្តរភាពនៃសេវាសុខភាពផ្លូវភេទ បន្តពូជ សេវាសុខភាពមាតា និងសេវាសុខភាពទារកទើបកើត ដែលសុទ្ធតែជាសេវាចាំបាច់សំខាន់ៗ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ កាលពីខែ មេសា ឆ្នាំ ២០២០។ ជាមួយនឹងការបន្តអនុវត្តគោលការណ៍ណែនាំ ដែលមានសារៈសំខាន់ទាំងនេះ ក៏ដូចជា ការកែសម្រួលកម្មវិធីឱ្យបានទាន់ពេលវេលា សេវាសុខភាពផ្លូវភេទ បន្តពូជ សេវាសុខភាពមាតា និងសេវាសុខភាពទារកទើបកើត នៅតែបន្តដំណើរការ និងនៅតែមានសម្រាប់ស្ត្រី និងក្មេងស្រី។ អង្គការសហប្រជាជាតិ និងមជ្ឈមណ្ឌលជាតិសុខភាពមាតានិងកុមារ បន្តពិនិត្យតាមដាននិរន្តរភាពនៃការផ្តល់សេវាសុខភាពផ្លូវភេទ បន្តពូជ និងសុខភាពមាតា ដែលត្រូវបានចាត់ទុកថាជាសេវាសំខាន់ៗ នៅទូទាំងប្រទេស ក៏ដូចជា លើភាពងាយស្រួលក្នុងការទទួលបានសេវាទាំងនេះ ជាពិសេស ពីសំណាក់ក្រុមដែលងាយរងគ្រោះ។ កាលពីឆ្នាំ ២០២០៖

- ការវាយតម្លៃបែបរហ័ស ដែលធ្វើឡើងផ្ទៃក្នុង លើការទទួលបានសេវាសុខភាពផ្លូវភេទ បន្តពូជ និងមាតា និងសេវាឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រចំនួនពីរជុំ ក្នុងចំណោមការវាយតម្លៃ

ទាំងបីជុំ ក្នុងអំឡុងពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ត្រូវបានធ្វើឡើង កាលពីដើម និងចុងខែ ឧសភា ឆ្នាំ ២០២១។ ការតម្លៃជុំចុងក្រោយនឹងធ្វើឡើងនៅក្នុងខែ កក្កដា ឆ្នាំ ២០២១។ ការផ្សព្វផ្សាយព័ត៌មានតាមបណ្តាញទំនាក់ទំនងសង្គម ក៏កំពុងត្រូវបានរៀបចំឡើងផងដែរ ដើម្បីឆ្លើយតបចំពោះបញ្ហានានាដែលត្រូវបានរកឃើញដោយការវាយតម្លៃនេះ។

- កុមារអាយុក្រោម ៥ឆ្នាំ ចំនួន ១២០ ៤៤៨នាក់ និងស្ត្រីមានផ្ទៃពោះចំនួន ៣៦១ ០០០នាក់ បានទទួលផលពីសេវាចាំបាច់សំខាន់ៗ ក្នុងខេត្តភូមិភាគឦសាននៃប្រទេសកម្ពុជា ដោយមានការអនុវត្តតាមវិធានការបម្រុងប្រយ័ត្ន ដើម្បីការពារជំងឺកូវីដ-១៩ផងដែរ។
- ឪពុកម្តាយ/អាណាព្យាបាលចំនួន ៨ ៥៤៣នាក់ (៥ ០៥៥នាក់) បានទទួលសេវាថែទាំសុខភាពមាតា ព័ត៌មានអំពីអំពើហិង្សាទាក់ទងយេនឌ័រ និងការគាំទ្រផ្លូវចិត្ត។
- យុវជនចំនួន ៨៣ ០៥៤ (ស្រី ៥៥ ០១៦នាក់) បានរាយការណ៍ថាបានប្រើប្រាស់សេវាសុខភាពដែលមានលក្ខណៈមេត្រីភាព ចំពោះក្មេងជំទង់ និងយុវជន នៅក្នុងខេត្តអាទិភាពទាំង ៨។

ដើម្បីឱ្យការទប់ស្កាត់ និងការឆ្លើយតប ចំពោះករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីក្លាយជាផ្នែកមួយដ៏សំខាន់នៃការឆ្លើយតបរបស់ប្រទេស ចំពោះជំងឺកូវីដ-១៩ អង្គការសហប្រជាជាតិបន្តជំរុញ ឱ្យរាជរដ្ឋាភិបាលការពារ និងលើកកម្ពស់សិទ្ធិស្ត្រី និងក្មេងស្រី ដូចជា (i) ចាត់ទុកថាការផ្តល់ថវិកាគាំទ្រដល់សេវាចាំបាច់សំខាន់ៗថាជាអាទិភាព និងបង្កើនភាពទន់ភ្លន់ក្នុងការផ្តល់ថវិកាគាំទ្រ ដល់ស្ថាប័នដែលធ្វើការងារដើម្បីស្ត្រី (ii) ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការដាក់ចេញនូវគោលនយោបាយជាតិ មិនអត់ឱនជាដាច់ខាតចំពោះករណីអំពើហិង្សាប្រភេទនេះ និងរៀបចំជាយុទ្ធនាការកៀរគរចលនានៅក្នុងសង្គម (iii) កែសម្រួលសេវានានា ឱ្យស្របតាមបរិបទនៃជំងឺកូវីដ-១៩ (iv) កែសម្រួលក្របខ័ណ្ឌច្បាប់ ដើម្បីធានាឱ្យមានភាពអនុលោមតាមបទដ្ឋាន និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ រួមទាំងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទផងដែរ និង (v) ប្រមូលទិន្នន័យ ដើម្បីធ្វើឱ្យសេវា និងកម្មវិធីឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រកាន់តែមានភាពល្អប្រសើរ។

###

ឯកសារព័ត៌មានស្តីពីការឆ្លើយតបរបស់អង្គការសហប្រជាជាតិនៅកម្ពុជាចំពោះបញ្ហាកូវីដ-១៩ គឺជាឯកសារផ្លូវការដែលផលិតដោយអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីផ្សព្វផ្សាយជូនអ្នកសារព័ត៌មាន និងដៃគូដទៃទៀត។ ឯកសារទាំងនេះត្រូវបានរៀបចំដោយការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនងនិងស្វែងរកការគាំទ្រនៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា តាមរយៈអ៊ីមែល៖ sreysros.keo@un.org។